# ស្ទឹឡាត់តាហ្វាច់យ៉ុដ

## ស្ទឹឡាត់យប់

اهل البيت
អាស្ុលុល-បៃត៍

ស្វឺឡាត់តាហាច់យុដ(ស្វឺឡាត់យប់)មាន ១១ រ៉ក់អាត់ ដែលប្រជុំស្វឺឡាត់ណាវ៉ាហ្វីឡាទុល-ឡៃលី(៨ រ៉ក់អាត់) ស្វឺឡាត់អាស់ស្វាហ្វ៊អាស់(២ រ៉ក់អាត់) និងស្វឺឡាត់អាល់-វិតរ៍(១ រ៉ក់អាត់) ។

ចូរជ្រាបថា សេចក្តីរាយការណ៍របស់ម៉ាក់ស្វ៊មីនពាក់ព័ន្ធនឹងស្វឺឡាត់យប់នោះមានច្រើនណាស់ ថ្លែងអំពីមគ្គផលដែលបានមកពីការងើបពេលយប់ ។ គេបានឲ្យដឹងថានេះគឺសេចក្តីថ្លៃថ្នូររបស់អ្នកមានជំនឿ ។ ចូរដឹងថា ស្វឺឡាត់យប់នាំមកនូវសុខភាពផ្លូវកាយ វាជាពិន័យលើបណ្តាបាបដែលបានប្រព្រឹត្តនៅពេលថ្ងៃ ហើយវាជាការលុបបំបាត់សេចក្តីឯកោនៅក្នុងផ្នូរ ។ វាធ្វើឲ្យមុខមានសម្បុរស វាធ្វើឲ្យមានក្លិនក្រអូប ព្រមទាំងនាំមកនូវធនធាន ។ "ទ្រព្យសម្បត្តិនិងបុត្រាបុត្រីជាគ្រឿងតែងលំអរបស់ជីវិតលោកនោះ (ស៊.១៨, អា.៤៦)" ព្រមទាំង ៨ រ៉ក់អាត់នៅពេលចុងរាត្រីកាលផងដែរ ។ រីឯរ៉ក់អាត់សេស(អាល់-វិតរ៍)នោះវិញជាការតែងលំអរបស់លោកមុខ ។ អល់ឡោះហ៊ុ ﷻ បានប្រមូលរ៉ក់អាត់ទាំងនេះសម្រាប់មនុស្សមួយប្រភេទ ។ អ្នកណាថាអ្នកបំពេញស្វឺឡាត់យប់ជាអ្នកស្រេកឃ្លាន អ្នកនោះនិយាយកុហកព្រោះស្វឺឡាត់យប់មាននូវធនធានរបស់ពេលថ្ងៃ ។

ពេលវេលារបស់ស្វឺឡាត់យប់គឺ ចាប់ពីពាក់កណ្តាលយប់ទៅ ។ កាន់តែជិតទៅពេល ស្វ៊ុបហ៍ស្វ៊ឌិក្ន កាន់តែបានផលច្រើន ។ បើសិនជាថ្ងៃចាប់ផ្តើមរះ តែអ្នកស្វឺឡាត់បានស្វឺឡាត់តែ ៤ រ៉ក់អាត់ ចូរឲ្យអ្នកនោះសូត្រតែអាល់ហ៊ាំដ៍សម្រាប់រ៉ក់អាត់ឯទៀតក៏បានដែរ ។

របៀបបំពេញស្វឺឡាត់យប់គឺ ៖

-៨ រ៉ក់អាត់ដំបូង ។ យើងស្វឺឡាត់ដោយនៀតថា ណាវ៉ាហ្វីឡាទុល-ឡៃលី តាស្វាស់ហ៊្វដ្ឋម្តងរាល់ៗពីររ៉ក់អាត់ ។ យកល្អឲ្យសូត្រស៊ូរ៉ោះត៍អាល់-អ៊ីខ្លាស្វ(ស៊ូរ៉ោះត៍ ១១២) ៦០ ដង ។ ក្នុងពីររ៉ក់អាត់ដំបូង គេសូត្រ ៣០ ដងក្នុងរ៉ក់អាត់នីមួយៗ ក្រោយពីសូត្រអាល់-ហ៊ាំដ៍រួច ដើម្បីនឹងជម្រុះបាបអស់រវាងបុគ្គលនឹងអល់ឡោះហ៊ុតាអាឡាពេលស្វឺឡាត់ចប់ ។

-ឬឲ្យសូត្រ ក្រោយអាល់-ហ្វាំដ៏ ក្នុងរ៉ក់អ៊ាត់ទីមួយ ស៊ូរ៉ោះត៍អាល់-អ៊ីខ្លាស្វ(ស៊ូរ៉ោះត៍ ១១២) ហើយក្នុងរ៉ក់អ៊ាត់ទីពីរឲ្យសូត្រស៊ូរ៉ោះត៍អាល់-កាហ្វីរូន(ស៊ូរ៉ោះត៍ ១០៩)។ សម្រាប់រ៉ក់អ៊ាត់ឯទៀត ឲ្យសូត្រ ក្រោយអាល់-ហ្វាំដ៏ ស៊ូរ៉ោះត៍មួយណាក៏បាន ស្រេចតែចិត្ត។

-ដូចគ្នាដែរ គ្រាន់តែសូត្រអាល់-ហ្វាំដ៏និងស៊ូរ៉ោះត៍អាល់-អ៊ីខ្លាស្វ(ស៊ូរ៉ោះត៍ ១១២)គ្រប់រ៉ក់អ៊ាត់ក៏បាន។ គេអនុញ្ញាតឲ្យសូត្រតែអាល់-ហ្វាំដ៏គ្រប់ៗរ៉ក់អ៊ាត់ផងដែរ។

-គូនូតក្នុងរ៉ក់អ៊ាត់ទាំង ៨ នេះ ដូចនៅក្នុងស្វ៊ឡាត់វ៉ាយីបដែរ គេបានផ្ដែផ្ដាំឲ្យសូត្រឌូអាអ៍ក្នុងស្វ៊ឡាត់ស៊ូណាត់ផងដែរក្នុងរ៉កអ៊ាត់ទីពីរគ្រប់ៗពីររ៉ក់អ៊ាត់។ ក្នុងគូនូត គ្រាន់តែសូត្រ៖

-៣ ដងថា سُبْحَانَ اللهِ (សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ៍) ក៏បាន។

-ឬសូត្រថា៖

اللَّهُمَّ اغْفِرْ لَنَا وَارْحَمْنا وَعَافِنَا وَاعْفُ عَنَّا فِي الدُّنْيَا والْآخِرَةِ إِنَّكَ عَلى كُلِّ شَيْءٍ قَدِيْرٌ (ឱអល់ឡោះហ៍ សូមព្រះអង្គលើកលែងទោសឲ្យអស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គមេត្តាប្រណីដល់អស់ទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គប្រទានសុខភាពល្អ/ចាកផុតគ្រោះ សូមព្រះអង្គប្រទានចំណែករបស់អស់ទូលព្រះបង្គំជាខ្ញុំ សម្រាប់លោកនេះនិងលោកមុខឲ្យអស់ទូលព្រះបង្គំជាខ្ញុំផង ព្រោះព្រះអង្គទ្រង់មានសព្វានុភាពលើសព្វសារពើ។)

-ឬសូត្រថា៖ رَبِّ اغْفِرْ وَارْحَمْ وَتَجاوَزْ عَمَّا تَعْلَمُ إِنَّكَ أَنْتَ الأَعَزُّ الأَجَلُّ الأَكْرَمْ (ព្រះម្ចាស់អើយ សូមព្រះអង្គលើកលែងទោសនិងមេត្តាប្រោសប្រណី សូមព្រះអង្គមានខន្តីចំពោះអ្វីដែលព្រះអង្គទ្រង់ញាណ ព្រោះព្រះអង្គមានសព្វានុភាពបំផុត ព្រះអង្គទ្រង់មហារុងរឿងបំផុត ព្រះអង្គមានព្រះហឫទ័យទូលំទូលាយបំផុត។)

-រ៉ក់អ៊ាត់ អាស្វ៉ស្វាហ្វ៍អ៊ាស់(រ៉ក់អ៊ាត់គូ) និងរ៉ក់អ៊ាត់ អាល់-វិតរ៍(រ៉ក់អ៊ាត់សេស)។ លុះបាន

ស៊ូឡាត់ ៨ រ៉ក់អ៊ាត់យប់រួចហើយ ឲ្យស៊ូឡាត់អាស់ស្វាហ្វ់អ៊ាស់ពីររ៉ក់អ៊ាត់និងស៊ូឡាត់អាល់-វិតរ៍មួយរ៉ក់អ៊ាត់ទៀត ។ ក្នុងរ៉ក់អ៊ាត់ទាំងបីនេះ ក្រោយពីបានសូត្រអាល់-ហ្វាំដ៏រួច ឲ្យសូត្រស៊ូរ៉ោះត៍អាល់-អ៊ិខ្លាស់(ស៊ូរ៉ោះត៍ ១១២)ដើម្បីទទួលបាននូវរង្វាន់ដោយសារតែបានសូត្រគួរអានចប់ ព្រោះថាសូត្រស៊ូរ៉ោះត៍អាល់-អ៊ិខ្លាស់បានមកនូវរង្វាន់មួយភាគបីនៃការសូត្រគួរអាន ។

-ឬក៏សូត្រ ក្នុងរ៉ក់អ៊ាត់ទីមួយរបស់ស៊ូឡាត់អាស់ស្វាហ្វ់អ៊ាស់ ស៊ូរ៉ោះត៍អាល់-ហ្វាំដ៏និងស៊ូរ៉ោះត៍អាន់-ណាស់(ស៊ូរ៉ោះត៍ ១១៤) ។ ក្នុងរ៉ក់អ៊ាត់ទីពីរ ឲ្យសូត្រស៊ូរ៉ោះត៍អាល់-ហ្វាំដ៏និងស៊ូរ៉ោះត៍អាល់-ហ្វាឡាក់(ស៊ូរ៉ោះត៍ ១១៣) ។

-ពេលស៊ូឡាត់អាស់ស្វាហ្វ់អ៊ាស់ចប់ យកល្អឲ្យបួងសួងអល់ឡោះហ៊ុំដូចតទៅគឺ៖

اِلهِي تَعَرَّضَ لَكَ فِي هذَا اللَّيْلِ الْمُتَعَرِّضُوْنَ وَ قَصَدَكَ الْقَاصِدُوْنَ وَ اَمَّلَ فَضْلَكَ وَ مَعْرُوْفَكَ الطَّالِبُوْنَ وَ لَكَ فِي هذَا اللَّيْلِ نَفَحَاتٌ وَ جَوائِزُ وَ عَطَايَا وَ مَوَاهِبُ تَمُنُّ بِهَا عَلى مَنْ تَشَاءُ مِنْ عِبَادِكَ وَ تَمْنَعُهَا مَنْ لَمْ تَسْبِقْ لَهُ الْعِنَايَةُ مِنْكَ وَهَا أَنَا ذَا عُبَيْدُكَ الْفَقِيْرُ إِلَيْكَ الْمُؤَمِّلُ فَضْلَكَ وَمَعْرُوْفَكَ فَاِنْ كُنْتَ يَا مَوْلاَيَ تَفَضَّلْتَ فِي هذِهِ اللَّيْلَةِ عَلى اَحَدٍ مِنْ خَلْقِكَ وَ عُدْتَ عَلَيْهِ بِعَائِدَةٍ مِنْ عَطْفِكَ فَصَلِّ عَلى مُحَمَّدٍ وَ آلِ مُحَمَّدٍ الطَّيِّبِيْنَ الطَّاهِرِيْنَ الْخَيِّرِيْنَ الْفَاضِلِيْنَ وَ جُدْ عَلَيَّ بِطَوْلِكَ وَ مَعْرُوْفِكَ يَا رَبَّ الْعَالَمِيْنَ وَ صَلَّى اللّهُ عَلى مُحَمَّدٍ خَاتَمِ النَّبِيِّيْنَ وَ آلِهِ الطَّاهِرِيْنَ وَ سَلَّمَ تَسْلِيْمًا اِنَّ اللّهَ حَمِيْدٌ مَجِيْدٌ اَللّهُمَّ اِنِّي اَدْعُوْكَ كَمَا اَمَرْتَ فَاسْتَجِبْ لِي كَمَا وَعَدْتَ اِنَّكَ لَا تُخْلِفُ الْمِيْعَادَ

(ឱព្រះរបស់ទូលព្រះបង្គំជាខ្ញុំអើយ បណ្តាអ្នកដែលបានបង្ហាញខ្លួនចំពោះព្រះអង្គគឺបណ្តាអ្នកដែលមានវត្តមាន ។ បណ្តាអ្នកដែលបានចរចារកព្រះអង្គគឺបណ្តាអ្នកដែលចរចា ។ បណ្តាអ្នកដែលសង្ឃឹមនឹងបាននូវព្រះឧបការធម៌ព្រះអង្គ និងព្រះសប្បុរសធម៌ព្រះអង្គគឺបណ្តាអ្នកដែលសូម ។ នៅក្នុងយប់នេះ ព្រះអង្គប្រទាននូវជំនួន រង្វាន់ អំណោយ និងធនានុគ្រោះ ឲ្យបាវបម្រើព្រះអង្គមួយណាដែលព្រះអង្គទ្រង់មានព្រះបំណង ។ ព្រះអង្គបង្អត់អ្វីទាំងនេះចំពោះអ្នកណាដែលមិនបានទទួលសេចក្តីរាប់អានរបស់ព្រះអង្គ ។ ទូលព្រះបង្គំជាខ្ញុំមកហើយ បាវបម្រើរបស់ព្រះអង្គ ដែលត្រូវការព្រះអង្គ ដែលសង្ឃឹមលើព្រះអនុគ្រោះព្រះអង្គនិងលើព្រះឧបការគុណព្រះអង្គ ។ ព្រះម្ចាស់

ទូលព្រះបង្គំជាខ្ញុំអឺយ បើព្រះអង្គប្រទានព្រះអនុគ្រោះព្រះអង្គឲ្យសត្វលោកណាមួយក្នុងចំណោមសត្វលោកទាំងឡាយរបស់ព្រះអង្គ ក្នុងយប់នេះ ហើយបែរទៅរកអ្នកនោះដោយសេចក្ដីស្រឡាញ់មែននោះ សូមព្រះអង្គទ្រង់ប្រទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់និងក្រុមគ្រួសាររបស់មូហាំម៉ាដ់ ដែលជាបណ្ដាបុគ្គលត្រឹមត្រូវ ដែលជាបណ្ដាអ្នកបរិសុទ្ធ ដែលជាបណ្ដាអ្នកសុក្រឹតឥតខ្ចោះ និងដែលជាបណ្ដាអ្នកប្រសើរបំផុត ហើយសូមព្រះអង្គមានព្រះហឫទ័យទូលំទូលាយមកលើរូបទូលព្រះបង្គំជាខ្ញុំផងដោយនូវព្រះអនុគ្រោះព្រះអង្គនិងដោយនូវព្រះសប្បុរសធម៌ព្រះអង្គ ឱព្រះម្ចាស់នៃភពទាំងឡាយអឺយ! សូមអល់ឡោះហ៍ប្រទានពរជ័យសិរីសួស្ដីដល់មូហាំម៉ាដ់ ព្រះសាស្ដាចុងក្រោយបង្អស់ក្នុងចំណោមព្រះសាស្ដាទាំងឡាយ និងដល់ព្រះរាជកុលដ្ឋានបរិសុទ្ធរបស់ព្រះអង្គ និងសូមព្រះអង្គរាប់រកបុគ្គលទាំងនេះដោយសេចក្ដីរាប់រកឥតខ្ចោះ ព្រោះអល់ឡោះហ៍សមជាទីលើកតម្កើងនិងសមជាទីកោតសរសើ ។ ឱព្រះរបស់ទូលព្រះបង្គំជាខ្ញុំអឺយ ទូលព្រះបង្គំជាខ្ញុំបួងសួងព្រះអង្គដូចដែលព្រះអង្គបានបញ្ជាឲ្យទូលព្រះបង្គំជាខ្ញុំបួងសួង ដូច្នេះសូមព្រះអង្គឆ្លើយតបទូលព្រះបង្គំជាខ្ញុំវិញដូចដែលព្រះអង្គបានសន្យាហើយនោះ ព្រោះព្រះអង្គមិនក្បត់ពាក្យសន្យាព្រះអង្គទេ ។

-ចប់ស៊ូឡាត់អាស្សាហ្វអ្សុ ងើបឡើងវិញដើម្បីបំពេញស៊ូឡាត់អាល់-វិតរ៍ ។ ក្នុងស៊ូឡាត់នេះឲ្យសូត្រស៊ូរ៉ោះត៍អាល់-ហ៊ាំដ៍និងស៊ូរ៉ោះត៍អាល់-អ៊ីខ្លាស្វ(ស៊ូរ៉ោះត៍ ១១២) ។

-ឬក៏សូត្រ ក្រោយស៊ូរ៉ោះត៍អាល់-ហ៊ាំដ៍ ស៊ូរ៉ោះត៍អាល់-អ៊ីខ្លាស្វ(ស៊ូរ៉ោះត៍ ១១២) ៣ ដង និងស៊ូរ៉ោះត៍សូមជម្រក ពោលគឺស៊ូរ៉ោះត៍អាន់-ណាស់(ស៊ូរ៉ោះត៍ ១១៤)និងស៊ូរ៉ោះត៍អាល់-ហ្វាឡាក់(ស៊ូរ៉ោះត៍ ១១៣) ។ ចប់ហើយ លើកដៃគូនូត បួងសួងសូមអ្វីស្រេចតែចិត្ត ។

-លោកទុសស៊ីបានថា គូនូតមានច្រើនណាស់ កុំពន្យារពេលឲ្យយូរឡើយ ។

-ប្រសើរឲ្យបួងសួងសូមអល់ឡោះហ៍ឲ្យបងប្អូនរួមសាសនា ឲ្យរំលឹកឈ្មោះពួកគេចំនួន ៤០ នាក់ ។ អ្នកណាបួងសួងអល់ឡោះហ៍ឲ្យអ្នកមានសទ្ធា ៤០ នាក់ ការបួងសួងរបស់អ្នកនោះនឹង

បានសម្រេចដូចបំណង  បើអល់ឡោះហ៍មានព្រះបំណង ។